**សលាកប័ត្រព័ត៌មាន ៖** ការប្រើកម្លាំងហួសហេតុទៅលើបាតុកម្មរបស់កម្មករ
**កាលបរិច្ឆេទ ៖** ខែវិច្ឆិកា ឆ្នាំ២០១៣
**ទិដ្ឋភាពរួម៖** ការប៉ុនប៉ងដ៏ហិង្សាយ៉ាងខ្លាំងរបស់អាជ្ញាធរថ្មីៗនេះក្នុងការបំបែកបាតុកម្មដែលកម្មករធ្វើឡើង គឺជាគំរូមួយទៀតដែលបង្ហាញឲ្យឃើញពីការមិនគោរពសិទ្ធិសេរីភាពខាងបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ លើកឡើងទិដ្ឋភាពរួមនៃបាតុកម្ម ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយកម្មករនិយោជិតរបស់រោងចក្រកាត់ដេរ អេស អិល នៅក្នុងរាជធានីភ្នំពេញ ដែលក្នុងអំឡុងពេលនោះនគរបាលបានប្រើប្រាស់គ្រាប់រំសេវគ្រោះថ្នាក់ដល់អាយុជីវិត ដោយបានសម្លាប់ស្ត្រីម្នាក់នៅក្បែរកន្លែងកើតហេតុឈ្មោះ អេង សុខុម និងបណ្តាលឲ្យមនុស្សចំនួន ៩ នាក់ផ្សេងទៀតរងរបួស។ បាតុករ និងព្រះសង្ឃមួយចំនួនក៏ត្រូវវាយដំយ៉ាងដំណំដោយនគរបាលនៅកន្លែងកើតហេតុ។ ឧបទ្ទវហេតុទាំងនេះ ជាកិច្ចប្រឹងប្រែងក្នុងកម្រិតខ្ពស់របស់មន្ត្រីអនុវត្តច្បាប់ដើម្បីបំបែកដោយហិង្សាលើបាតុកម្ម ដែលជាការរំលោភបំពានលើច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិនានា។ សលាកប័ត្រព័ត៌មាននេះចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស កម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## សាវតារ

ឧស្សាហកម្មកាត់ដេរនៅកម្ពុជាមានការកើនឡើងយ៉ាងលឿន និងមានកំណើនឋិតថេរនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ មានការប៉ាន់ប្រមាណថា កម្មករកម្មការិនីយ៉ាងហោចណាស់ចំនួន ៤៧៥.១០៧ នាក់ធ្វើការដោយផ្ទាល់នៅក្នុងឧស្សាហកម្មកាត់ដេរ។ ទោះជាយ៉ាងនេះក្តី ខណៈដែលឧស្សាហកម្មនេះមានគុណប្រយោជន៍ជាខ្លាំងលើសេដ្ឋកិច្ចរបស់ប្រទេសជាតិ ឧស្សាហកម្មកាត់ដេរត្រូវបានជះឥទ្ធិពលដោយលក្ខខណ្ឌការងារពុំទាន់ប្រសើរគ្រប់គ្រាន់ ប្រាក់ឈ្នួលទាប និងកិច្ចសន្យារយៈពេលខ្លី ដែលមានការធានាសុវត្ថិភាពការងារតិចតួចបំផុត។ ទាំងកម្មករ និងតំណាងសហជីពនៅរោងចក្រកាត់ដេរ អេស អិល ដែលជារោងចក្រផលិតសម្លៀកបំពាក់ឲ្យក្រុមហ៊ុន Gap និង H&M បានចំណាយពេលជាងបីខែមកហើយដើម្បីទាមទារលក្ខខណ្ឌការងារឲ្យល្អប្រសើរឡើង បង្កើនប្រាក់ឈ្នួលប្រចាំខែ និងដកមន្ត្រីកងរាជអាវុធហត្ថស្លៀកសម្លៀកបំពាក់ស៊ីវិលដែលត្រូវបានជួលដើម្បីការពារសុវត្ថិភាពនៅរោងចក្រ។ ចាប់តាំងពីខែសីហា ឆ្នាំ២០១៣ កម្មកររោងចក្រ អេស អិល ជាច្រើននាក់បានធ្វើកូដកម្ម និងបាតុកម្មជាបន្តបន្ទាប់ ដែលពេលខ្លះត្រូវទទួលរងនូវការតបតវិញយ៉ាងហិង្សាពីសំណាក់កងកម្លាំងប្រដាប់អាវុធ។ ជាឧទាហរណ៍ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ មន្ត្រីកងរាជអាវុធហត្ថមួយចំនួនដែលបានជួលឲ្យការពាររោងចក្រកាត់ដេរ បានបាញ់គ្រាប់រំសេវគ្រោះថ្នាក់ដល់អាយុជីវិតទៅលើមេឃ ពីលើក្រុមកម្មករ និងបាតុករ ព្រមទាំងបានវាយដំទៅលើបុរសម្នាក់យ៉ាងធ្ងន់ធ្ងរ។ យ៉ាងណាក៏ដោយ ឧបទ្ទវហេតុនេះគឺគ្រាន់តែជាផ្នែកដ៏តូចមួយនៃបញ្ហាប៉ុណ្ណោះ បើធៀបទៅនឹងអ្វីដែលបានកើតឡើងបន្ទាប់ទៀតកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។

## ការប្រើកម្លាំងហួសហេតុ

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ កម្មករកាត់ដេរមួយក្រុមប្រមាណជា ៦០០ នាក់បានព្យាយាមដើរក្បួនតវ៉ាពីទីតាំងរោងចក្រ អេស អិល នៅខណ្ឌស្ទឹងមានជ័យទៅកាន់គេហដ្ឋានរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមានទីតាំងស្ថិតនៅកណ្តាលរាជធានីភ្នំពេញ ដែលជាកន្លែងកម្មករតវ៉ាទាំងនោះគ្រោងនឹងធ្វើបាតុកម្ម។ នគរបាលបង្ក្រាបកុបករ ដែល

បំពាក់ដោយខែល និងដំបង ព្រមទាំងអមជាមួយនឹងរថយន្តពន្លត់អគ្គិភ័យមួយចំនួន បានជួបប្រទះជាមួយនឹងក្រុមកម្មករកាត់ដេរនៅចំណុចក្បែរស្ពានស្ទឹងមានជ័យ ដើម្បីរារាំងការដើរក្បួននោះ។

ដំបូងឡើយ ក្រុមបាតុករបានដើរសំដៅនគរបាលបង្ក្រាបកុបករដោយឥរិយាបថប្រកបដោយសន្តិវិធី ដែលមានកាន់ស្លាកសញ្ញាធ្វើដោយដៃ និងទាមទារឲ្យខ្លួនអាចដើរបន្តទៅមុខទៀតបាន។ ជាយថាហេតុ នគរបាលបង្ក្រាបកុបករ ដែលមានជំនួយពីឡានបាញ់ទឹក បានចាប់ផ្តើមធ្វើឲ្យក្រុមកម្មករត្រឡប់ទៅទិសដៅដែលកម្មករបានចេញមក។ ហេតុការណ៍នេះបានជំរុញឲ្យប្រជាពលរដ្ឋនៅតំបន់នោះចូលរួមជាមួយក្រុមបាតុករ។ រំពេចភ្លាមនោះ ដុំថ្ម និងគ្រាប់រើងផ្សេងៗត្រូវបានគប់លើនគរបាលបង្ក្រាបកុបករ។ ក្រោយមក នគរបាលបានដកថយនៅឆ្ងាយពីស្ពាន តែបន្សល់ទុកនូវរថយន្តនគរបាលមួយគ្រឿង ហើយមន្ត្រីនគរបាលមួយចំនួននៅក្នុងបរិវេណវត្តស្ទឹងមានជ័យ។ បន្ទាប់មកទៀត ក្រុមបាតុករបានក្រឡាប់ និងដុតរថយន្តនគរបាលមួយគ្រឿង និងម៉ូតូនគរបាល។

មនុស្សមួយក្រុមធំបានប្រមូលផ្តុំគ្នានៅខាងក្រៅជុំវិញអគារ ដែលមន្ត្រីនគរបាលបីនាក់បានលាក់ខ្លួននៅទីនោះ។ ដំបូងឡើយ ព្រះសង្ឃមួយក្រុមបានឃាត់អ្នកទាំងនោះមិនឲ្យចូលបរិវេណវត្ត ប៉ុន្តែ ទីបំផុត បានបើកផ្លូវវិញ ដោយសារតែក្រុមមនុស្សទាំងនោះបានមកដល់អគារដោយទម្លុះចូលតាមទ្វារ ហើយបានគំរាមកំហែងដល់មន្ត្រីទាំងបីនាក់នោះ ព្រមទាំងបានដោះសព្វាវុធ ខែល និងដំបងចេញពីខ្លួនរបស់មន្ត្រីទាំងនោះ។ ក្រោយមក មន្ត្រីទាំងបីនាក់បានគេចចេញផុតពីបរិវេណវត្ត។

កងកម្លាំងប្រដាប់អាវុធ ដែលបានបង្កើនចំនួនយ៉ាងច្រើនភ្លាមៗនោះ បានធ្វើចលនាចេញពីទីតាំងរបស់ខ្លួននៅស្ពានស្ទឹងមានជ័យ។ ក្រុមបាតុករបានគប់ដុំថ្មទៅលើកងកម្លាំងប្រដាប់អាវុធ ហើយក្រុមកងកម្លាំងក៏បានតបតវិញដោយបាញ់ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់កៅស៊ូ និងគ្រាប់រំសេវគ្រោះថ្នាក់ដល់អាយុជីវិតទៅលើក្រុមបាតុករ និងទៅក្នុងបរិវេណវត្តស្ទឹងមានជ័យ។ បន្ទាប់មកទៀត កងកម្លាំងប្រដាប់អាវុធបានផ្ទុកចូលទៅក្នុងបរិវេណវត្ត ហើយបានដេញ និងវាយដំលើបាតុករមួយចំនួន។ ហេតុដូច្នេះហើយ ទើបបាតុករខ្លះបានរត់គេចខ្លួនចេញពីវត្តតែម្តង។ អ្នកសារព័ត៌មានរបស់កាសែត *ខែម ប៊ូខៃ ដេលី* ម្នាក់បានឃើញមន្ត្រីនគរបាលម្នាក់ ដែលជាប់នៅក្នុងវត្តមុននេះ លើកកាំភ្លើងខ្លីរបស់គាត់ ហើយបាញ់និស្សិតប្រុសម្នាក់ឈ្មោះ ហឿន ច័ន្ទ ត្រូវចំដងខ្លួន។

បីបួនម៉ោងក្រោយមក ការប៉ះទង្គិចគ្នាយ៉ាងអនាធិបតេយ្យជាបន្តបន្ទាប់បានកើតឡើងរវាងក្រុមបាតុករ និងកងកម្លាំងប្រដាប់អាវុធ។ នៅក្នុងអំឡុងពេលនៃភាពច្របូកច្របល់នោះ ស្ត្រីលក់ដូរតាមផ្លូវ វ័យ ៤៩ ឆ្នាំម្នាក់ឈ្មោះ អេង សុខុម ដែលជាអ្នកនៅក្បែរកន្លែងកើតហេតុមិនបានចូលរួមជាមួយនឹងបាតុកម្ម បានត្រូវគ្រាប់ដែលបាញ់ចេញពីកាំភ្លើងរបស់នគរបាល ហើយត្រូវបានបញ្ជាក់ថាស្លាប់នៅពេលទៅដល់មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ មានសេចក្តីបញ្ជាក់ថា លោក ហឿន ច័ន្ទ ឥឡូវនេះត្រូវពិការអស់មួយជីវិត។ បាតុករចំនួន ៨ នាក់ផ្សេងទៀតក៏ត្រូវរបួសដោយសារតែកាំភ្លើងរបស់នគរបាល និងមួយចំនួនផ្សេងទៀតត្រូវបាននគរបាលវាយនឹងដំបងយ៉ាងដំណំ។

លោកអ្នកអាចមើលភស្តុតាងនៃអំពើហិង្សានេះតាមរយៈវីដេអូរបស់កាសែត *ឌឹ ភ្នំពេញ ប៉ុស្តិ៍* និងអង្គការ លីកាដូ។

**សេរីភាពខាងការបញ្ចេញមតិ និង សេរីភាពខាងការជួបប្រជុំ**

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ

ពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ បញ្ញត្តថា ប្រជាពលរដ្ឋខ្មែរមាន "សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការប្រជុំ" ខណៈដែលមាត្រា ៣១ ចែងថា ប្រទេសកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចដែលមានចេញនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ដែលការពារសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការធ្វើបាតុកម្ម ពុំបានគ្របដណ្តប់លើការប្រមូលផ្តុំទាក់ទិននឹងវិវាទការងារនៅខាងក្នុង ឬ ជិតបរិវេណរោងចក្រ ឬ សហគ្រាសនោះទេ តែយ៉ាងណាក៏ដោយ បាតុកម្មកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ គឺស្ថិតនៅចម្ងាយឆ្ងាយសមល្មមពីរោងចក្រអេស អិល។

**ការអនុវត្តន៍ច្បាប់ និង ការប្រើប្រាស់កម្លាំង**

លិខិតូបករអន្តរជាតិមួយចំនួនគ្រប់គ្រង និងបញ្ញត្តអំពីការណែនាំជាសកល ដែលអធិប្បាយពីបទដ្ឋានអប្បបរមាសម្រាប់ការប្រតិបត្តិរបស់មន្ត្រីអនុវត្តច្បាប់ រួមបញ្ចូលទាំងបញ្ហាជាក់លាក់មួយចំនួនដូចជា វិសាលភាពកម្រិតណាដែលការប្រើប្រាស់កម្លាំងអាចត្រូវបានអនុវត្តត្រឹមត្រូវតាមច្បាប់។ លក្ខខណ្ឌតម្រូវទាំងនេះ មានដូចគ្នាទៅនឹងនិយមន័យនៃការការពារស្របច្បាប់តាមមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាផងដែរ។

មុននឹងពិចារណាលើការប្រើប្រាស់កម្លាំង និងអាវុធ ត្រូវតែប្រើប្រាស់វិធានការទាំងឡាយឲ្យអស់លទ្ធភាពដើម្បីស្វែងរកដំណោះស្រាយដោយអហិង្សាជាមុនសិន។ កម្លាំងត្រូវតែប្រើប្រាស់នៅពេលដែលមានករណីចាំបាច់បំផុតតែប៉ុណ្ណោះ និងជានិច្ចកាលត្រូវសមាមាត្រទៅនឹងគោលបំណងតាមផ្លូវច្បាប់។ អាវុធត្រូវប្រើប្រាស់តែក្នុងកាលៈទេសៈពិសេសបំផុត ហើយនឹងត្រូវប្រើប្រាស់ដើម្បីតែការការពារស្របច្បាប់ ឬ ការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដល់អាយុជីវិត ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដែលនឹងកើតមានតែប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ ការប្រើប្រាស់កម្លាំង និងអាវុធស្លាប់រស់នឹងអនុញ្ញាតទៅបានតែក្នុងពេលដែលមិនអាចជៀសរួចដើម្បីការពារអាយុជីវិតរបស់មនុស្ស។

ដោយផ្អែកតាមប្រភពព័ត៌មានមួយចំនួន រួមទាំងការលើកឡើងផ្ទាល់របស់សាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងករណីនេះថា កងកម្លាំងប្រដាប់អាវុធខកខានជាខ្លាំងក្នុងការបំពេញតាមបទដ្ឋានអន្តរជាតិដែលទទួលស្គាល់។ នគរបាលបំពេញការងារក្នុងឥរិយាបថដែលគ្មានវិន័យ មិនមានសមាមាត្រទាល់តែសោះ និងខ្វះការគោរពយ៉ាងពេញលេញចំពោះសុវត្ថិភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ។ កងកម្លាំងប្រដាប់អាវុធបានបាញ់ដោយគ្មានការរើសអើងទៅលើក្រុមកូដកររបស់រោងចក្រ អ្នកនៅក្បែរហេតុការណ៍ និងប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋាន ដែលស្ថិតនៅជិតក្មេងៗរាប់រយនាក់ដែលកំពុងតែរៀននៅក្នុងសាលាទល់មុខវត្តស្ទឹងមានជ័យ។

**សេចក្តីសន្និដ្ឋាន និង អានុសាសន៍**

លទ្ធផលក្រោយបាតុកម្មរបស់កម្មកររោងចក្រ អេស អិល ឃើញថា មនុស្ស ៣៨ នាក់ត្រូវបានចាប់ខ្លួន (៣១ នាក់ជាពលរដ្ឋស៊ីវិល និងព្រះសង្ឃ ៧ អង្គ) រួមទាំងអនីតិជនមួយចំនួនផង ដែលសង្ស័យថាបានចូលរួមហេតុការណ៍នោះ។ អ្នកដែលត្រូវបានចាប់ខ្លួនភាគច្រើនត្រូវបានដោះលែង ប៉ុន្តែអនីតិជន ២ នាក់ រួមទាំងម្នាក់ដែលគេដឹងថាមានបញ្ហាស្មារតី ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅមជ្ឈមណ្ឌលអប់រំកែប្រែព្រៃសរនាពជធានីភ្នំពេញ។ នៅតែមានក្តីបារម្ភជាខ្លាំងលើការស៊ើបអង្កេតអំពីការបាញ់ប្រហារ និងការប្រើប្រាស់កម្លាំងហួសហេតុ ស្របពេលដែលពុំទាន់មានមន្ត្រីអនុវត្តច្បាប់ដែលជាប់ពាក់ព័ន្ធនឹងបញ្ហានេះត្រូវបានចាប់ខ្លួននៅឡើយទេ។ ហេតុការណ៍នេះជាឧបទ្ទវហេតុចុងក្រោយនៃការធ្វើបាតុកម្មសាធារណៈជាបន្តបន្ទាប់ ដែលទទួលការតបតយ៉ាងហិង្សាពីសំណាក់មន្ត្រីអនុវត្តច្បាប់។ ករណីនេះមានសភាពធ្ងន់ធ្ងរ ដោយហេតុដែលថា

ហិង្សាប្រឆាំងនឹងបាតុករកើតមានជាញឹកញាប់ជាងការដោះស្រាយលើបញ្ហានិទណ្ឌភាព។ ហេតុដូច្នេះ ម.ស.ម.ក ជំរុញឲ្យមានការស៊ើបអង្កេតជាបន្ទាន់មួយ ដើម្បីជានាឲ្យមានទំនួលខុសត្រូវយ៉ាងពេញលេញទៅលើការប្រើប្រាស់កម្លាំងហួសហេតុ ព្រមទាំងអំពាវនាវឲ្យផ្អាកជាបន្ទាន់នូវភ្នាក់ងារអនុវត្តច្បាប់ទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងបាតុកម្ម រហូតដល់មានការពិនិត្យសើរើឡើងវិញឲ្យបានពេញលេញលើហេតុការណ៍នេះ។ យើងក៏សូមអំពាវនាវឲ្យអាជ្ញាធរជានាថា អនីតិជនដែលត្រូវបានចាប់ខ្លួន ត្រូវបានប្រព្រឹត្តយ៉ាងត្រឹមត្រូវអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងជានាឲ្យមានការថ្លឹងថ្លែងពិចារណាដ៏ត្រឹមត្រូវត្រូវចំពោះលក្ខខណ្ឌជាក់លាក់របស់អនីតិជនទាំងនោះ។

ម.ស.ម.ក សូមថ្កោលទោសលើការប្រើប្រាស់ហិង្សាណាមួយដោយមនុស្សគ្រប់គ្នា និងស្នើដល់បាតុករត្រូវជានាថា ការធ្វើបាតុកម្មទាំងឡាយប្រព្រឹត្តទៅដោយសន្តិវិធី។ ម.ស.ម.ក សូមក្រើនរម្លឹកដល់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ថា គ្មានជនណាម្នាក់ត្រូវបានបដិសេធតាមអំពើចិត្តចំពោះសិទ្ធិរស់រានមានជីវិតរបស់ខ្លួន ឬ ត្រូវទទួលរងនូវការដាក់ទណ្ឌកម្មដែលពុំសមាមាត្រនោះទេ។ បន្ថែមលើនេះទៀត រដ្ឋាភិបាលមានភារកិច្ចក្នុងការជានាថា សេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីត្រូវបានគោរពយ៉ាងពេញលេញ និងត្រូវជានាថា កងកម្លាំងសន្តិសុខត្រូវគោរពឲ្យបានខ្ជាប់ខ្ជួនចំពោះ "គោលការណ៍ជាមូលដ្ឋានស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ ដោយមន្ត្រីអនុវត្តច្បាប់" របស់អង្គការសហប្រជាជាតិ និង "ក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់"។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងប្រធាន ម.ស.ម.ក លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ +៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬ តាមរយៈអ៊ីមែល ouvirak@cchrcambodia.org ឬ អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សរបស់ ម.ស.ម.ក លោក ឌុច ពិសិដ្ឋ តាមរយៈលេខ +៨៥៥ (0) ១២ ៧១ ២៣ ៧១ ឬតាមរយៈអ៊ីមែល duchpiseth@cchrcambodia.org។**